គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៦ ចេញផ្សាយថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១
No. 6 Released on August 09, 2021

# អត្ថបទប្រចាំសប្តាហ៍ | Weekly Article

## បរធនបាលកិច្ចសង្គម | Social Trust



រូបភាព | Picture: https://cbk.bschool.cuhk.edu.hk/wp-content/uploads/shutterstock_1310240776-e1571040129807.jpg

បរធនបាលកិច្ចសង្គម ត្រូវបានបង្កើតឡើងនៅពេលដែល បរធនបាលទាយក ធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅបរធន-បាល ដើម្បីប្រើប្រាស់ជាប្រយោជន៍ទូទៅក្នុងសង្គម ដូចជាគោលបំណង វប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ (ច្បាប់ស្តីពីបរធន-បាលកិច្ច, ២០១៩)។ លក្ខណៈបរធនបាលកិច្ចសង្គមត្រូវបានកំណត់ ជា ២ ដូចខាងក្រោម៖

**១).** មូលនិធិពិសេស៖ **ក.** មូលនិធិដែលបង្កើតដោយបរធន-បាលទាយកតាមរយៈប្រទានកម្ម ឬមតកសាសន៍, **ខ.** តាមរយៈការ ទទួលទ្រព្យសម្បត្តិ ពីអ្នកផ្តល់វិភាគទានបរធនបាលកិច្ចនៅមានជីវិត ឬទទួលទ្រព្យសម្បត្តិតាមមតកសាសន៍ របស់អ្នកផ្តល់វិភាគទានបរ-ធនបាលកិច្ច និង, **គ.** ទ្រព្យសម្បត្តិត្រូវបានផ្ទេរឱ្យទៅបរធនបាល ដើម្បី បំពេញគោលបំណងជាប្រយោជន៍សង្គម និង, **ឃ.** មិនស្វែងរកប្រាក់ ចំណេញឬគ្មានប្រតិបត្តិការជាសហគ្រាសពាណិជ្ជកម្ម និង, **ង.** លើក លែងតែមានចែងផ្សេងក្នុងលិខិតបរធនបាលកិច្ច ទ្រព្យសម្បត្តិដំបូង និងទ្រព្យសម្បត្តិបន្ថែមផ្សេងទៀត ដែលអ្នកផ្តល់វិភាគទានបរធនបាល-កិច្ចបានផ្ទេរចូលមូលនិធិណាមួយ ត្រូវរក្សាទុកដើម្បីបំពេញគោល-បំណងបរធនបាលកិច្ច ហើយអនុញ្ញាតឱ្យចែកចាយតែផលដែលបាន ពីទ្រព្យសម្បត្តិនោះប៉ុណ្ណោះ។

**២).** មូលនិធិសម្រាប់ជាប្រយោជន៍ដល់អង្គការវប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ៖ ទ្រព្យសម្បត្តិទទួលពីបុគ្គល រួមមានប្រទានកម្ម ឬមតកសាសន៍ ហើយទ្រព្យសម្បត្តិនេះត្រូវបាន ផ្ទេរដើម្បីបម្រើគោលដៅសម្រាប់ជាប្រយោជន៍ ជាអាទិ៍ វប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ។

A social trust is established when a trust creator contributes his asset to the trustee for general social purposes such as cultural, educational, human, religious, or scientific purposes (Law on Trust, 2019). The nature of social trust is defined as two as follows:

**1).** Special Fund: **A.** Funds created by the trust creator through donations or inheritance, **B.** By receiving asset from a surviving trust contributor or receiving asset by inheritance from a trust contributor and, **C.** Assets are transferred to the trustee for social purposes and, **D.** Non-profit or no operation as a commercial enterprise and, **E.** Except as otherwise stated in the letter of trust, the initial asset and any additional asset transferred by the trust contributor to any fund shall be retained for the purpose of trust and is permitted to be distributed only to the proceeds of that asset.

**2).** Funds for the benefit of cultural, educational, human, religious, or scientific organizations: asset received from individuals include donations or inheritance, and these assets are transferred to serve purposes such as culture, education, humanity, religion, or science.

**ឯកសារយោង | References**:

- ច្បាប់ស្តីពីបរធនបាលកិច្ច. (២០១៩).

**អត្ថបទ៖ឃុន វាសនា | Article: Veasna Khun**

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

www.facebook.com/trustregulatorcambodia
អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.